រាជបណ្ឌិត្យសភាកម្ពុជា

# ចំណេះដឹងនិងឥរិយាបថរបស់ប្រជាជន
# ចំពោះសុខភាព
# នៅមណ្ឌលសុខភាពអូររាំងខេត្តមណ្ឌលគិរី

រៀបចំដោយៈ វេជ្ជ. នុត សម្បត្តិ និង វេជ្ជ. ជួន គីមចេង
ពិនិត្យនិងកែសម្រួលៈ ឯឧ. បណ្ឌិត ស៊ុន សូត
វិទ្យាស្ថាន ជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្មនៃរាជបណ្ឌិត្យសភាកម្ពុជា
ឧបត្ថម្ភដោយៈ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី

ភ្នំពេញ ២០១៣

## សមាជិកស្រាវជ្រាវ

១- ឯកឧត្តម បណ្ឌិតសភាចារ្យ ជាណេង

២- ឯកឧត្តម  បណ្ឌិត ស៊ុន សូត

៣- វេជ្ជបណ្ឌិត  ជួន គីមចេង

៤- លោកបណ្ឌិត  នុត សម្បត្តិ

៥- លោកបណ្ឌិត  ម៉ុងស៊ាងងីម

៦- លោក ស្វាយរីដា

៧- លោកបណ្ឌិត ជូ ចាន់ដារី

# ១_សេចក្តីផ្តើម

ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដោយមានប្រជាជនប្រមាណ ៣៦% រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ (NIS 2005) ជាង៩១%នៃប្រជាជនក្រីក្ររស់នៅតាមជនបទ (World Bank 2006)។ មានកត្តាចម្បងពីរសំខាន់ ដែលមានទំនាក់ទំនងរវាងភាពក្រីក្រ និងសុខភាពគឺ កង្វះលទ្ធភាព និងចំណេះដឹងអំពីសុខភាព ដែលមាន ទំនាក់ទំនងគ្នាទៅវិញទៅមកជាខ្សែចង្វាក់។ បញ្ហាសុខភាព កង្វះលទ្ធភាព ឬ ការបង់ប្រាក់សម្រាប់សេវាសុខភាពហួសពីលទ្ធភាពរបស់ប្រជាជន អាចនាំទៅរកភាពក្រីក្រ និងការអន់ថយនៃការអភិវឌ្ឍសេដ្ឋកិច្ច។ ចំពោះប្រជាជនក្រីក្រនៅតាមជនបទ បញ្ហាសុខភាព អាចជារឿងជោគវាសនា ដែលមានផលវិបាកយ៉ាងខ្លាំងសម្រាប់ពួកគាត់។ ប្រជាជនខ្លះបាន លក់គោ ដីស្រែនិងទ្រព្យសម្បត្តិ ដើម្បីជួយសង្គ្រោះជីវិតពីជំងឺធ្ងន់ធ្ងរ និងពីការស្លាប់នៃសមាជិកគ្រួសាររបស់ពួកគាត់ ដែលជាហេតុនាំឱ្យពួកគាត់មានការបាត់បង់ទ្រព្យសម្បត្តិ និងធ្លាក់ខ្លួនក្រ។ ជាការពិតនៅប្រទេសកម្ពុជាជំងឺជាមូលហេតុចម្បងនៃភាពក្រីក្រ។ ថ្វីត្បិតតែស្ថានភាពសុខភាពបច្ចុប្បន្ន មានភាពប្រសើរជាងមុនក៏ដោយ ប៉ុន្តែប្រជាជននៅតាមតំបន់ដាច់ស្រយាល មានស្ថានភាពសុខភាព និង ការយល់ដឹងអំពីបញ្ហាសុខភាពនៅមានកម្រិតទាបនៅឡើយ។ យោងតាមលទ្ធផលនៃការអង្កេត ប្រជា

សាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ ២០០៥ បង្ហាញឱ្យឃើញថា មានតែប្រជាជនប្រមាណ ២២% ប៉ុណ្ណោះ ដែលបានដឹង និងប្រើប្រាស់សេវាសុខភាពសាធារណៈ ប្រជាជនប្រមាណជាង ២០% ស្វែងរកការថែទាំមិនមែនវេជ្ជសាស្ត្រ ដូចជា គ្រូខ្មែរ ព្រះសង្ឃ និងឆ្មបបុរាណ ។ល ។ ឱសថស្ថាននិងហាងលក់ថ្នាំ គ្លីនិចឯកជនជាកន្លែង សម្រាប់ព្យាបាលប្រជាជន ប្រមាណ ៤៨%នៃប្រជាជនទាំងអស់ (DHS 2005) ។ ទោះបីប្រទេសកម្ពុជាត្រូវបានមើលឃើញថា មានការថយចុះនូវអត្រាមរណៈភាពរបស់មាតា និងកុមារអាយុក្រោម៥ឆ្នាំក៏ដោយ ក៏អត្រានេះនៅមានកម្រិតខ្ពស់ ជាពិសេសបើប្រៀបធៀបជាមួយនឹងបណ្តាប្រទេសជិតខាង ដោយអត្រាមរណៈភាពរបស់មាតាមានកម្រិត ២០៦ នៅលើ ១០០.000 កំណើតរស់ និងអត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំមានកម្រិត៥៤ លើ ១.000 កំណើតរស់ ( CDHS 2010) ។ ចំណែកបញ្ហាអនាម័យ កង្វះមីក្រូសារជាតិ ក្នុងចំណោមស្ត្រីនិងកុមារអាយុក្រោម៥ឆ្នាំវិញគឺនៅតែជាបញ្ហាសុខភាពសាធារណៈដ៏ធ្ងន់ធ្ងរនៅប្រទេសកម្ពុជានៅឡើយ ។

តើពួកគេអាចជាសះស្បើយ ពីជំងឺប្រកបដោយប្រសិទ្ធភាព ដែរឬទេ បើពួកគេមិនបានទទួលការណែនាំ ពីបុគ្គលិកសុខាភិបាល និងការតាម ដានជំងឺឱ្យបានច្បាស់លាស់ត្រឹមត្រូវ? ឯការប្រើប្រាស់ឱសថ ក៏មិនសមស្រប ទាំងនេះជាមូលហេតុសំខាន់ចាំបាច់ សម្រាប់ការសិក្សាស្រាវជ្រាវនេះ ។

# ២_គោលបំណង

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងវាយតម្លៃលើស្ថានភាពចំណេះដឹងរបស់ប្រជាជនចំពោះសុខភាពមូលដ្ឋាន អំពីឥរិយាបថ និងការអនុវត្ត ហើយនិងការប្រើប្រាស់សេវាសុខាភិបាលសាធារណៈ នៅតាមសហគមន៍ជនបទដាច់ស្រយាល ។

- ស្ថានភាពចំណេះដឹងរបស់ប្រជាជនចំពោះសុខភាពមូលដ្ឋាន ឥរិយាបថ និងការប្រព្រឹត្ត ហើយនិងការប្រើប្រាស់សេវាសុខាភិបាលសាធារណៈ នៅតាមសហគមន៍ជនបទដាច់ស្រយាល មិនមានភាពល្អប្រសើរឡើយ បើប្រៀបធៀបនឹងលទ្ធផលប្រជាសាស្ត្រនិងសុខភាពឆ្នាំ ២០០៥ ។
- ចំណេះដឹងរបស់ប្រជាជនចំពោះសុខភាពមូលដ្ឋាន ឥរិយាបថ និងការប្រព្រឹត្ត ហើយនិងការប្រើប្រាស់សេវាសុខាភិបាលសាធារណៈនៅតាមសហគមន៍ជនបទដាច់ស្រយាល មានភាពប្រសើរជាងមុន បើប្រៀបធៀបនឹងលទ្ធផលប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥ ។

# ៣. វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ទីតាំងភូមិសាស្ត្រ

មណ្ឌលសុខភាពអូររាំងគ្របដណ្តប់លើឃុំចំនួន២គឺ ឃុំសែនមនោរម្យ និងឃុំដាក់ដាំ និង ១០ភូមិ ។ មណ្ឌលសុខភាពនេះមានចំងាយ ប្រមាណ ៥ គីឡូម៉ែត្រ ពីទីរួមខេត្តមណ្ឌលគិរី មានប្រជាជនសរុបប្រមាណ ៤១៧១ នាក់ កុមារអាយុក្រោម៥ឆ្នាំមាន ៤៤៨នាក់ និងស្ត្រីក្នុងវ័យបន្តពូជមានចំនួន ២៤៥៦ ។




មណ្ឌលសុខភាព ស្រុកអូររាំង



សកម្មភាពរបស់ក្រុមការងារជួបប្រជុំជាមួយនឹងបុគ្គលិកមណ្ឌលសុខភាព

## ៣.២ វិធីសាស្ត្រ

វិធីសាស្ត្រស្រាវជ្រាវធ្វើឡើងតាមរយៈកម្រងសំណួរសំភាសន៍ ជាមួយប្រជាជនគោលដៅ ដោយប្រើវិធីសាស្ត្រសិក្សាជាចង្កោម ដោយបែងចែកជា ១០ភូមិ ដែលក្នុងមួយភូមិមានប្រជាជនចំណុច ១២គ្រួសារ តាមការជ្រើសរើសដោយចៃដន្យ។ ការជ្រើសរើស ១២ គ្រួសារដោយចៃដន្យក្នុងភូមិនីមួយៗ នៅក្នុងគ្រួសារដែលមានក្មេង យ៉ាងហោចណាស់មួយនាក់អាយុក្រោម៥ឆ្នាំ។ ក្រុមមន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថាន ជីវសាស្ត្រវេជ្ជសាស្ត្រ និង កសិកម្ម នៃរាជបណ្ឌិត្យសភាកម្ពុជា ជាអ្នកជ្រើសរើសគ្រួសារដោយចៃដន្យ។ យើងធ្វើទំនាក់ទំនង ពីកាលបរិច្ឆេទជាមួយបុគ្គលិកមណ្ឌលសុខភាពដែលចូលរួមជាមួយនឹង ការសិក្សាស្រាវជ្រាវនេះ។ អ្នកសំភាសន៍មានពីរក្រុមហើយ ក្រុមនីមួយៗមានសមាជិក ២នាក់។ ការប្រមូលទិន្នន័យធ្វើឡើងតាមរយៈកម្រងសំណួរសំភាសន៍ បញ្ចូលទៅក្នុងនិងវិភាគតាមរយៈកុំព្យូទ័រ។



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិពូទ្រេង



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិងោល



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិពូហ្សាម



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិពូរាំង



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិរការថ្មី



សកម្មភាពចុះសម្ភាសន៍របស់ក្រុមការងារនៅភូមិអណ្តូងក្រឡឹង



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិពូឡេះ

# ៤. លទ្ធផល

## ៤.១ ឥរិយាបថនៃការស្វែងរកសេវាសុខភាព

ឥរិយាបថនៃការស្វែងរកសេវាសុខភាព ដើរតួយ៉ាងសំខាន់ក្នុងការសម្រេចចិត្ត អំពីបញ្ហាសុខភាពនិងស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ការស្វែងរកសេវាសុខភាពមិនបានត្រឹមត្រូវ អាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាព និងភាពក្រីក្រ ព្រោះវិធីដែលប្រជាជនស្វែងរកការថែទាំ សុខភាព នៅពេលដែលមានជំងឺ អាចមានឥទ្ធិពលបណ្តាលមកពីចំណេះដឹងខ្លួនឯងផ្ទាល់ និងគុណភាពនៃអ្នកផ្តល់ សេវាផងដែរ ដើម្បីដោះស្រាយបញ្ហាខាងលើ ក្រសួងសុខាភិបាលបានយកចិត្តទុកដាក់លើការផ្លាស់ប្តូរឥរិយាបថ ទំនាក់ទំនង និងយុទ្ធសាស្ត្របង្កើនគុណភាព នៅក្នុងគម្រោងយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ ២០០៣-២០០៧ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់សេវា សុខភាពសាធារណៈដែលត្រូវរំពឹងទុកថានឹងមានប្រសិទ្ធភាព និងមានលទ្ធភាព ចំពោះប្រជាពលរដ្ឋក្រីក្រ។

នៅក្នុងតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាពអូររាំង អ្វីៗហាក់ដូចជាប្រព្រឹត្តទៅបានល្អប្រសើរ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ មានសញ្ញាណនៃការផ្លាស់ប្តូរមួយចំនួន នៃឥរិយាបថក្នុងការស្វែងរកសេវាសុខភាព។ ក្នុងចំណោមអ្នកចូលរួមសម្ភាស ១១៧ នាក់ដែលបានសម្ភាស មានអ្នកចូលរួមចំនួន ៧១ (៦១%) ជាស្ត្រី និង (៣៩%) ជាបុរស អាយុជាមធ្យមគឺ ៤៨ (IQR: ៣៤-៦១)។ ស្ថានភាព

គ្រួសារនៃអ្នកចូលរួមគឺ នៅលីវ ១១% មានគ្រួសារ ៦៩% និង ១៦% និង៤% មេមាយនិងលែងលះ។ ចំពោះស្ថានភាពនៃការសិក្សាគឺ ៣២ (២៧%) នៃអ្នកចូលរួមគឺមិនមានការសិក្សា ៥២ (៤៤%) រៀនបានត្រឹមតែកម្រិតបឋមសិក្សា ២៥ (២១%) រៀនបានកម្រិតមធ្យមសិក្សា ហើយ ៨ (៧%) កម្រិតលើសមធ្យមសិក្សា។ ៩៦%នៃអ្នកចូលរួមមានមុខរបរជាកសិករឬជាកម្មករស៊ីឈ្នួល និង ៤% ជាមន្ត្រីរាជការ។

តារាងលក្ខណៈ ប្រជាសាស្ត្ររបស់អ្នកចូលរួមសម្ភាសន៍

| **General characteristic** | **Total (n=117)** |
|---|---|
| Age, median (IQR) | 48 (34-61) |
| Gender, n (%) | |
| Female | 71(61) |
| Male | 46 (39) |
| Marital status, n (%) | |
| single | 13 (11) |
| married | 81 (69) |
| widowed | 19 (16) |
| divorced | 4 (4) |
| Education, n (%) | |
| no education | 32 (27) |
| primary school | 52 (44) |
| secondary school | 25 (21) |
| high school & over | 8 (7) |
| Employment, n (%) | |
| farmer/worker | 112 (96) |
| government staff | 5 (4) |
| Distance to HC, n (%) | |
| 1-5 km | 67 (70) |
| >5 km | 29 (30) |

ក្នុងចំណោមអ្នកចូលរួមទាំងអស់មាន ១០៣ នាក់ (៨៨%) បានរាយការណ៍ថា ពួកគាត់បានទៅរកពេទ្យនៅពេលដែលសមាជិកគ្រួសារមានជំងឺ ហើយមានតែ ១២% ដែលបានបន់ស្រន់អ្នកតាឬសែនព្រេន។ ក្នុងចំណោមអ្នកដែលបានជ្រើសរើសពេទ្យជាជម្រើសទី១ នៅពេលមានសមាជិកក្នុងក្រុមគ្រួសារឈឺ ការជ្រើសរើសមណ្ឌលសុខភាពជាកន្លែងទី១ ដើម្បីព្យាបាលនៅពេលសមាជិកក្នុងគ្រួសារមានជំងឺមាន ៧៣ (៧១%) ដែលក្នុងនោះអ្នកចូលរួម ២១ នាក់ (២០%) នៅតែជ្រើសរើស យកសេវាព្យាបាលឯកជននៅឡើយ។ តួលេខបានបង្ហាញឱ្យឃើញពីសញ្ញាណនៃការផ្លាស់ប្តូរ បើប្រៀបធៀបទៅនឹងការធ្វើអង្កេតមួយនៅឆ្នាំ ២០០០ ដែលបង្ហាញឱ្យឃើញពីសមមាត្រ ៤៦% នៃប្រជាជនដែលជ្រើសរើសមកព្យាបាល នៅមណ្ឌលសុខភាព និង ៤៤% ជ្រើសរើសសេវាឯកជន។ ទោះបីជាយ៉ាងណា ក៏ដោយ ការព្យាបាលដោយខ្លួនឯង ហើយការព្យាបាលផ្សេងទៀត ដូចជា គ្រូបូរាណ និង ការព្យាបាលមិន ច្បាស់លាស់ផ្សេងៗ នៅតែមានសកម្មភាពក្នុង កម្រិតទាបនិងមិនកែប្រែ។

ឥរិយាបថក្នុងការស្វែងរកសេវាសុខាភិបាល




ហេតុផលនៃការប្រើប្រាស់សេវាសុខាភិបាលពេលសមាជិកគ្រួសារមាន
ជំងឺ
Percent
45
40
35
30
25
20
15
10
5
0
Distance
Cost
Staff competency
Availability of drugs
Staff behaviour
Availability of service
other

មធ្យោបាយទៅកាន់មណ្ឌលសុខភាព និង តម្លៃសេវា នៅតែជាកត្តាដំបូង ក្នុងការសម្រេចចិត្តជ្រើសរើសសេវាសុខភាពសាធារណៈ ក្នុងចំណោមប្រជាជនទាំងនោះ។ ក្នុងចំណោមអ្នកដែលបានធ្វើការសម្ភាសមាន ៤២% បានជ្រើសរើសសេវាកម្មនៅមូលដ្ឋានដោយគិតជាចម្ងាយផ្លូវពីផ្ទះរបស់ពួកគាត់។ ពោលគឺមានន័យថា ស្ថានភាពភូមិសាស្ត្ររបស់សហគមន៍ នៅតែជាកង្វល់ជាអទិភាពរបស់ប្រជាជននិងភ្នាក់ងារសុខាភិបាលផងដែរ។ ប្រជាជនហាក់ដូចជាទទួលយកតម្លៃសេវាកម្មច្រើនជាងមុន អ្នកចូលរួម ៤០% បានឱ្យដឹងថា សេវាកម្មថោកគឺជាមូលដ្ឋានក្នុងសម្រេចចិត្តថាត្រូវទៅទីណានៅពេលដែលសមាជិកក្នុងគ្រួសារមានជំងឺ។ មូលហេតុដទៃទៀតដូចជា សមត្ថភាព និង អាកប្បកិរិយារបស់បុគ្គលិកសុខាភិបាល ឱសថ និងសេវាកម្ម មិនចោទជាសំខាន់ទេក្នុងការសម្រេចចិត្តជ្រើសរើសសេវាថែទាំសុខភាព។

## ៤.២ ការយល់ដឹងអំពីការប្រើប្រាស់ម្សៅអូរ៉ាលីត ( ORS )

**(ORS)** ត្រូវបានចាត់ទុកថា ជាសារធាតុមួយដ៏មានប្រសិទ្ធភាពដែលអាចជួយសង្គ្រោះជីវិតកុមារ ដែលបាត់បង់ជាតិទឹកដោយសារជំងឺរាក ក្អួត និងជំងឺផ្សេងៗទៀត។ វាជាបញ្ហាចាំបាច់ ដែលមាតាគ្រប់រូបត្រូវយល់ដឹងឱ្យបានច្បាស់អំពីសារប្រយោជន៍នៃម្សៅអូរ៉ាលីត និងរបៀបប្រើប្រាស់វាឱ្យបានត្រឹមត្រូវ។ ការវាយតម្លៃលើការអង្កេតបានបង្ហាញឱ្យឃើញថា ការយល់ដឹងរបស់

ម្តាយចំពោះការប្រើប្រាស់ម្សៅ អូរ៉ាលីត (ORS) មាន ៩៤% ។ នៅក្នុងចំណោមអ្នកដែលបានដឹងអំពីម្សៅអូរ៉ាលីត ៩៧% បានប្រើប្រាស់សម្រាប់ជំងឺរាក ហើយ ១៤% សម្រាប់ក្អួត និង ១២% សំរាប់មូលហេតុផ្សេងៗទៀត ។ គួរកត់ សម្គាល់ថា សមាមាត្រនៃស្ត្រីដែលបានដឹងអំពីរបៀបប្រើប្រាស់ម្សៅអូរ៉ាលីតត្រឹមត្រូវដែលក្នុង១កញ្ចប់នៃម្សៅអូរ៉ាលីតគឺលាយទឹកឆ្អិនចំណុះមួយលីតមាន ៧៩% ។


ចំណេះដឹងអំពីការប្រើប្រាស់ម្សៅអូរ៉ាលីត
94.8
5.2
100
50
0
percent
Know
Don't know

## ៤.៣ ការយល់ដឹងអំពីជំងឺផ្លូវដង្ហើមស្រួចស្រាវ (ARI)

ARI នៅតែជាមូលហេតុបណ្តាលឱ្យកុមារអាយុក្រោម ៥ ឆ្នាំស្លាប់ក្ន ប្រទេសកម្ពុជា។ ការស្វែងរកសេវាសុខភាពមិនបានត្រឹមត្រូវ និងកង្វះខា ចំណេះដឹងរបស់ម្តាយ ឬ អ្នកមើលថែរទាំកុមារ អំពីសញ្ញាគ្រោះថ្នាក់នៃ AI លើកុមារជាកត្តាចំបងដែលធ្វើឱ្យកុមារ ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។ ក្ន ចំណោមអ្នកចូលរួម ១១៧ នាក់ ដែលបានសម្ភាស មានតែ ៨% ដែលមិនបា ដឹងអ្វីទាំងអស់អំពីសញ្ញាគ្រោះថ្នាក់ធ្ងន់ធ្ងរនៃ ARI។ ប្រជាជនភាគច្រើនបា ដឹងអំពី រោគសញ្ញា គ្រុនក្តៅ ៧០.៦% ហៀរសំបោរ ៦០.២% ក្អក ៧៥.២ ចង្វាក់ដង្ហើមញាប់ ៤៨.៧% និងពិបាកដកដង្ហើម ២៧.៧% ថាជាសញ្ញារលា សួតធ្ងន់ធ្ងរ។


ការប្រៀបធៀបចំណេះដឹងរបស់ម្តាយអំពីសញ្ញានៃការរលាកផ្លូ
វ ដង្ហើមស្រួចស្រាវ
80
60
40
20
0
Percent
70.6
60.2
75.2
25.7
48.7
27.7
5.7
High fever
Runing nose
Cough
Headache
Fash breathing
Breathing dificulty
Don't know
Warning Signs

## ៤.៤ ការយល់ដឹងអំពីជម្ងឺគ្រុនចាញ់ និងការប្រើប្រាស់មុង

ជំងឺគ្រុនចាញ់នៅតែជាបញ្ហាចម្បងនៅក្នុងប្រទេស។ ការយល់ដឹងនិងការអនុវត្តបានត្រឹមត្រូវ អាច ការពារខ្លួនពីការឆ្លងជម្ងឺនេះ។ ការអង្កេតបានបង្ហាញឱ្យឃើញថា ភាគច្រើនលើសលុបនៃប្រជាជនក្នុងតំបន់បានឱ្យដឹងថា ជម្ងឺគ្រុនចាញ់ គឺបណ្តាលមកពីមូសដែកគោលខាំមានប្រមាណ ៩៤.៦%។ ប្រជាជនដែលមិនបានដឹង អំពីមូលហេតុដែលបណ្តាលឱ្យកើតជំងឺគ្រុនចាញ់មានត្រឹមតែ ៤% ប៉ុណ្ណោះ។ មានតែប្រជាជនមួយផ្នែកតូច ដែលនៅមានជំនឿថា ជំងឺគ្រុនចាញ់បណ្តាលមកពីកត្តាអារក្សអ្នកតា ឬឥទ្ធិពលដទៃទៀត។ ៧៨% នៃអ្នកដែលចូលរួមបាន ឱ្យដឹងថាសមាជិកក្រុមគ្រួសារគាត់ដេកក្នុងមុងជានិច្ចកាល។ សម្រាប់អ្នកដែលមិនបានប្រើប្រាស់មុងឱ្យបានទៀងទាត់ ហើយលទ្ធភាពដែលអាចរកមុងបាន និង លុយដើម្បីទិញមុងហាក់ដូចជាពុំមានបញ្ហាធំដុំទេ មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះ ដែលបានលើកចំណុចនោះជាហេតុផលបញ្ហាចម្បងគឺ ទម្លាប់មិនដេកក្នុងមុង ដែលមានកម្រិតខ្ពស់ ៣៨% ហើយការដែលជឿថា គ្មានមូសនៅក្នុងនិងជុំវិញតំបន់នោះក៏ខ្ពស់ផងដែរ ២៥.៤% មានហេតុផលមិនច្បាស់លាស់ដទៃទៀតបានរួមចំណែកក្នុងការមិនប្រើប្រាស់ឱ្យបានទៀងទាត់។


ចំណេះដឹងស្តីអំពីជំងឺគ្រុនចាញ់
94.6
1.7
1
4
100
80
60
40
20
0
Percent
Moquito bite
Spirit
Other
Don't know
Malaria causes



អត្រានៃការប្រើប្រាស់មុង
78
18
4
80
60
40
20
0
Percent
Always
Sometime
Never

# សមាជិកស្រាវជ្រាវ

១- ឯកឧត្តម បណ្ឌិតសភាចារ្យ ជាណេង

២- ឯកឧត្តម   បណ្ឌិត ស៊ុន សូត

៣- វេជ្ជបណ្ឌិត  ជួន គីមចេង

៤- លោកបណ្ឌិត  នុត សម្បត្តិ

៥- លោកបណ្ឌិត  ម៉ុងស៊ាងងីម

៦- លោក ស្វាយរីដា

៧- លោកបណ្ឌិត ជូ ចាន់ដារី

# ១_សេចក្តីផ្តើម

ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដោយមានប្រជាជនប្រមាណ ៣៦% រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ (NIS 2005) ជាង៩១%នៃប្រជាជនក្រីក្ររស់នៅតាមជនបទ (World Bank 2006)។ មានកត្តាចម្បងពីរសំខាន់ ដែលមានទំនាក់ទំនងរវាងភាពក្រីក្រ និងសុខភាពគឺ កង្វះលទ្ធភាព និងចំណេះដឹងអំពីសុខភាព ដែលមាន ទំនាក់ទំនងគ្នាទៅវិញទៅមកជាខ្សែចង្វាក់។ បញ្ហាសុខភាព កង្វះលទ្ធភាព ឬ ការបង់ប្រាក់សម្រាប់សេវាសុខភាពហួសពីលទ្ធភាពរបស់ប្រជាជន អាចនាំទៅរកភាពក្រីក្រ និងការអន់ថយនៃការអភិវឌ្ឍសេដ្ឋកិច្ច។ ចំពោះប្រជាជនក្រីក្រនៅតាមជនបទ បញ្ហាសុខភាព អាចជារឿងជោគវាសនា ដែលមានផលវិបាកយ៉ាងខ្លាំងសម្រាប់ពួកគាត់។ ប្រជាជនខ្លះបាន លក់គោ ដីស្រែនិងទ្រព្យសម្បត្តិ ដើម្បីជួយសង្គ្រោះជីវិតពីជំងឺធ្ងន់ធ្ងរ និងពីការស្លាប់នៃសមាជិកគ្រួសាររបស់ពួកគាត់ ដែលជាហេតុនាំឱ្យពួកគាត់មានការបាត់បង់ទ្រព្យសម្បត្តិ និងធ្លាក់ខ្លួនក្រ។ ជាការពិតនៅប្រទេសកម្ពុជាជំងឺជាមូលហេតុចម្បងនៃភាពក្រីក្រ។ ថ្វីត្បិតតែស្ថានភាពសុខភាពបច្ចុប្បន្ន មានភាពប្រសើរជាងមុនក៏ដោយ ប៉ុន្តែប្រជាជននៅតាមតំបន់ដាច់ស្រយាល មានស្ថានភាពសុខភាព និង ការយល់ដឹងអំពីបញ្ហាសុខភាពនៅមានកម្រិតទាបនៅឡើយ។ យោងតាមលទ្ធផលនៃការអង្កេត ប្រជា

សាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ ២០០៥ បង្ហាញឱ្យឃើញថា មានតែប្រជាជនប្រមាណ ២២% ប៉ុណ្ណោះ ដែលបានដឹង និងប្រើប្រាស់សេវាសុខភាពសាធារណៈ ប្រជាជនប្រមាណជាង ២០% ស្វែងរកការថែទាំមិនមែនវេជ្ជសាស្ត្រ ដូចជា គ្រូខ្មែរ ព្រះសង្ឃ និងឆ្មបបុរាណ ។ល។ ឱសថស្ថាននិងហាងលក់ថ្នាំ គ្លីនិចឯកជនជាកន្លែង សម្រាប់ព្យាបាលប្រជាជន ប្រមាណ ៤៨%នៃប្រជាជនទាំងអស់ (DHS 2005) ។ ទោះបីប្រទេសកម្ពុជាត្រូវបានមើលឃើញថា មានការថយចុះនូវអត្រាមរណៈភាពរបស់មាតា និងកុមារអាយុក្រោម៥ឆ្នាំក៏ដោយ ក៏អត្រានេះនៅមានកម្រិតខ្ពស់ ជាពិសេសបើប្រៀបធៀបជាមួយនឹងបណ្តាប្រទេសជិតខាង ដោយអត្រាមរណៈភាពរបស់មាតាមានកម្រិត ២០៦ នៅលើ ១០០.០០០ កំណើតរស់ និងអត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំមានកម្រិត៥៤ លើ ១.០០០ កំណើតរស់ ( CDHS 2010) ។ ចំណែកបញ្ហាអនាម័យ កង្វះមីក្រូសារជាតិ ក្នុងចំណោមស្ត្រីនិងកុមារអាយុក្រោម៥ឆ្នាំវិញគឺនៅតែជាបញ្ហាសុខភាពសាធារណៈដ៏ធ្ងន់ធ្ងរនៅប្រទេសកម្ពុជានៅឡើយ ។

តើពួកគេអាចជាសះស្បើយ ពីជំងឺប្រកបដោយប្រសិទ្ធភាព ដែរឬទេ បើពួកគេមិនបានទទួលការណែនាំ ពីបុគ្គលិកសុខាភិបាល និងការតាម ដានជំងឺឱ្យបានច្បាស់លាស់ត្រឹមត្រូវ? ឯការប្រើប្រាស់ឱសថ ក៏មិនសមស្រប ទាំងនេះជាមូលហេតុសំខាន់ចាំបាច់ សម្រាប់ការសិក្សាស្រាវជ្រាវនេះ ។

# ២.គោលបំណង

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងវាយតម្លៃលើស្ថានភាពចំណេះដឹងរបស់ប្រជាជនចំពោះសុខភាពមូលដ្ឋាន អំពីឥរិយាបថ និងការអនុវត្ត ហើយនិងការប្រើប្រាស់សេវាសុខាភិបាលសាធារណៈ នៅតាមសហគមន៍ជនបទដាច់ស្រយាល ។

- ស្ថានភាពចំណេះដឹងរបស់ប្រជាជនចំពោះសុខភាពមូលដ្ឋាន ឥរិយាបថ និងការប្រព្រឹត្ត ហើយនិងការប្រើប្រាស់សេវាសុខាភិបាលសាធារណៈ នៅតាមសហគមន៍ជនបទដាច់ស្រយាល មិនមានភាពល្អប្រសើរឡើយ បើប្រៀបធៀបនឹងលទ្ធផលប្រជាសាស្ត្រនិងសុខភាពឆ្នាំ ២០០៥ ។
- ចំណេះដឹងរបស់ប្រជាជនចំពោះសុខភាពមូលដ្ឋាន ឥរិយាបថ និងការប្រព្រឹត្ត ហើយនិងការប្រើប្រាស់សេវាសុខាភិបាលសាធារណៈនៅតាមសហគមន៍ជនបទដាច់ស្រយាល មានភាពប្រសើរជាងមុន បើប្រៀបធៀបនឹងលទ្ធផលប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥ ។

# ៣. វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ទីតាំងភូមិសាស្ត្រ

មណ្ឌលសុខភាពអូររាំងគ្របដណ្តប់លើឃុំចំនួន២គឺ ឃុំសែនមនោរម្យ និងឃុំដាក់ដាំ និង ១០ភូមិ ។ មណ្ឌលសុខភាពនេះមានចំងាយ ប្រមាណ ៥ គីឡូម៉ែត្រ ពីទីរួមខេត្តមណ្ឌលគីរី មានប្រជាជនសរុបប្រមាណ ៤១៧១ នាក់ កុមារអាយុក្រោម៥ឆ្នាំមាន ៤៤៨នាក់ និងស្ត្រីក្នុងវ័យបន្តពូជមានចំនួន ២៤៥៦ ។




មណ្ឌលសុខភាព ស្រុកអូររាំង



សកម្មភាពរបស់ក្រុមការងារជួបប្រជុំជាមួយនឹងបុគ្គលិកមណ្ឌលសុខភាព

## ៣.២ វិធីសាស្ត្រ

វិធីសាស្ត្រស្រាវជ្រាវធ្វើឡើងតាមរយៈកម្រងសំណួរសំភាសន៍ ជាមួយប្រជាជនគោលដៅ ដោយប្រើវិធីសាស្ត្រសិក្សាជាចង្កោម ដោយបែងចែកជា ១០ភូមិ ដែលក្នុងមួយភូមិមានប្រជាជនចំណុច ១២គ្រួសារ តាមការជ្រើសរើសដោយចៃដន្យ។ ការជ្រើសរើស ១២ គ្រួសារដោយចៃដន្យក្នុងភូមិនីមួយៗ នៅក្នុងគ្រួសារដែលមានក្មេង យ៉ាងហោចណាស់មួយនាក់អាយុក្រោម៥ឆ្នាំ។ ក្រុមមន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថាន ជីវសាស្ត្រវេជ្ជសាស្ត្រ និង កសិកម្ម នៃរាជបណ្ឌិត្យសភាកម្ពុជា ជាអ្នកជ្រើសរើសគ្រួសារដោយចៃដន្យ។ យើងធ្វើទំនាក់ទំនង ពីកាលបរិច្ឆេទជាមួយបុគ្គលិកមណ្ឌលសុខភាពដែលចូលរួមជាមួយនឹង ការសិក្សាស្រាវជ្រាវនេះ។ អ្នកសំភាសន៍មានពីរក្រុមហើយ ក្រុមនីមួយៗមានសមាជិក ២នាក់។ ការប្រមូលទិន្នន័យធ្វើឡើងតាមរយៈកម្រងសំណួរសំភាសន៍ បញ្ចូលទៅក្នុងនិងវិភាគតាមរយៈកុំព្យូទ័រ។



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិពូទ្រង



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិងោល



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិពូហ្យាម



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិពូរាំង



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិរការថ្មី



សកម្មភាពចុះសម្ភាសន៍របស់ក្រុមការងារនៅភូមិអណ្តូងក្រឡឹង



សកម្មភាពចុះសម្ភាសន៍ របស់ក្រុមការងារនៅភូមិពូឡេះ

# ៤. លទ្ធផល

## ៤.១ ឥរិយាបថនៃការស្វែងរកសេវាសុខភាព

ឥរិយាបថនៃការស្វែងរកសេវាសុខភាព ដើរតួយ៉ាងសំខាន់ក្នុងការសម្រេចចិត្ត អំពីបញ្ហាសុខភាពនិងស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ការស្វែងរកសេវាសុខភាពមិនបានត្រឹមត្រូវ អាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាព និងភាពក្រីក្រ ព្រោះវិធីដែលប្រជាជនស្វែងរកការថែទាំ សុខភាព នៅពេលដែលមានជំងឺ អាចមានឥទ្ធិពលបណ្តាលមកពីចំណេះដឹងខ្លួនឯងផ្ទាល់ និងគុណភាពនៃអ្នកផ្តល់ សេវាផងដែរ ដើម្បីដោះស្រាយបញ្ហាខាងលើ ក្រសួងសុខាភិបាលបានយកចិត្តទុកដាក់លើការផ្លាស់ប្តូរឥរិយាបថ ទំនាក់ទំនង និងយុទ្ធសាស្ត្របង្កើនគុណភាព នៅក្នុងគម្រោងយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ ២០០៣-២០០៧ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់សេវា សុខភាពសាធារណៈដែលត្រូវរំពឹងទុកថានឹងមានប្រសិទ្ធភាព និងមានលទ្ធភាព ចំពោះប្រជាពលរដ្ឋក្រីក្រ។

នៅក្នុងតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាពអូររាំង អ្វីៗហាក់ដូចជាប្រព្រឹត្តទៅបានល្អប្រសើរ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ មានសញ្ញាណនៃការផ្លាស់ប្តូរមួយចំនួន នៃឥរិយាបថក្នុងការស្វែងរកសេវាសុខភាព។ ក្នុងចំណោមអ្នកចូលរួមសម្ភាស ១១៧ នាក់ដែលបានសម្ភាស មានអ្នកចូលរួមចំនួន ៧១ (៦១%) ជាស្ត្រី និង (៣៩%) ជាបុរស អាយុជាមធ្យមគឺ ៤៨ (IQR: ៣៤-៦១)។ ស្ថានភាព

គ្រួសារនៃអ្នកចូលរួមគឺ នៅលើវ ១១% មានគ្រួសារ ៦៩% និង ១៦% និង៤% មេមាយនិងលែងលះ។ ចំពោះស្ថានភាពនៃការសិក្សាគឺ ៣២ (២៧%) នៃអ្នកចូលរួមគឺមិនមានការសិក្សា ៥២ (៤៤%) រៀនបានត្រឹមតែកម្រិតបឋមសិក្សា ២៥ (២១%) រៀនបានកម្រិតមធ្យមសិក្សា ហើយ ៨ (៧%) កម្រិតលើសមធ្យមសិក្សា។ ៩៦%នៃអ្នកចូលរួមមានមុខរបរជាកសិករឬជាកម្មករស៊ីឈ្នួល និង ៤% ជាមន្ត្រីរាជការ។

តារាងលក្ខណៈប្រជាសាស្ត្ររបស់អ្នកចូលរួមសម្ភាសន៍

| General characteristic | Total (n=117) |
|---|---|
| Age, median (IQR) | 48 (34-61) |
| Gender, n (%) | |
| Female | 71(61) |
| Male | 46 (39) |
| Marital status, n (%) | |
| single | 13 (11) |
| married | 81 (69) |
| widowed | 19 (16) |
| divorced | 4 (4) |
| Education, n (%) | |
| no education | 32 (27) |
| primary school | 52 (44) |
| secondary school | 25 (21) |
| high school & over | 8 (7) |
| Employment, n (%) | |
| farmer/worker | 112 (96) |
| government staff | 5 (4) |
| Distance to HC, n (%) | |
| 1-5 km | 67 (70) |
| >5 km | 29 (30) |

ក្នុងចំណោមអ្នកចូលរួមទាំងអស់ មាន ១០៣ នាក់ (៨៨%) បានរាយការណ៍ថា ពួកគាត់បានទៅរកពេទ្យនៅពេលដែលសមាជិកគ្រួសារមានជំងឺ ហើយមានតែ ១២% ដែលបានបន់ស្រន់អ្នកតាឬសែនព្រេន។ ក្នុងចំណោមអ្នកដែលបានជ្រើសរើសពេទ្យជាជម្រើសទី១ នៅពេលមានសមាជិកក្នុងក្រុមគ្រួសារឈឺ ការជ្រើសរើសមណ្ឌលសុខភាពជាកន្លែងទី១ ដើម្បីព្យាបាលនៅពេលសមាជិកក្នុងគ្រួសារមានជំងឺមាន ៧៣ (៧១%) ដែលក្នុងនោះអ្នកចូលរួម ២១ នាក់ (២០%) នៅតែជ្រើសរើស យកសេវាព្យាបាលឯកជននៅឡើយ។ តួលេខបានបង្ហាញឱ្យឃើញពីសញ្ញាណនៃការផ្លាស់ប្តូរ បើប្រៀបធៀបទៅនឹងការធ្វើអង្កេតមួយនៅឆ្នាំ ២០០០ ដែលបង្ហាញឱ្យឃើញពីសមមាត្រ ៤៦% នៃប្រជាជនដែលជ្រើសរើសមកព្យាបាល នៅមណ្ឌលសុខភាព និង ៤៤% ជ្រើសរើសសេវាឯកជន។ ទោះបីជាយ៉ាងណា ក៏ដោយ ការព្យាបាលដោយខ្លួនឯង ហើយការព្យាបាលផ្សេងទៀត ដូចជា គ្រូបូរាណ និង ការព្យាបាលមិន ច្បាស់លាស់ផ្សេងៗ នៅតែមានសកម្មភាពក្នុង កម្រិតទាបនិងមិនកែប្រែ។


ឥរិយាបថក្នុងការស្វែងរកសេវាសុខាភិបាល
Percent
80
60
40
20
0
71
46
44
20
5
4
5
5
H.C
Private practitioners
Buy medicine/self treatment
other
Year 2000
Year 2013


ហេតុផលនៃការប្រើប្រាស់សេវាសុខាភិបាលពេលសមាជិកគ្រួសារមានជំងឺ
45
40
35
30
25
20
15
10
5
0
Percent
Distance
Cost
Staff competency
Availability of drugs
Staff behaviour
Availability of service
other

មធ្យោបាយទៅកាន់មណ្ឌលសុខភាព និង តម្លៃសេវា នៅតែជាកត្តាដំបូង ក្នុងការសម្រេចចិត្តជ្រើសរើសសេវាសុខភាពសាធារណៈ ក្នុងចំណោមប្រជាជនទាំងនោះ។ ក្នុងចំណោមអ្នកដែលបានធ្វើការសម្ភាសមាន ៤២% បានជ្រើសរើសសេវាកម្មនៅមូលដ្ឋានដោយគិតជាចម្ងាយផ្លូវពីផ្ទះរបស់ពួកគាត់។ ពោលគឺមានន័យថា ស្ថានភាពភូមិសាស្ត្ររបស់សហគមន៍ នៅតែជាកង្វល់ជាអទិភាពរបស់ប្រជាជននិងភ្នាក់ងារសុខាភិបាលផងដែរ។ ប្រជាជនហាក់ដូចជាទទួលយកតម្លៃសេវាកម្មច្រើនជាងមុន អ្នកចូលរួម ៤០% បានឱ្យដឹងថា សេវាកម្មថោកគឺជាមូលដ្ឋានក្នុងសម្រេចចិត្តថាត្រូវទៅទីណានៅពេលដែលសមាជិកក្នុងគ្រួសារមានជំងឺ។ មូលហេតុដទៃទៀតដូចជា សមត្ថភាព និង អាកប្បកិរិយារបស់បុគ្គលិកសុខាភិបាល ឱសថ និងសេវាកម្ម មិនចោទជាសំខាន់ទេក្នុងការសម្រេចចិត្តជ្រើសរើសសេវាថែទាំសុខភាព។

## ៤.២ ការយល់ដឹងអំពីការប្រើប្រាស់ម្សៅអូរ៉ាលីត (ORS)

**(ORS)** ត្រូវបានចាត់ទុកថា ជាសារធាតុមួយដ៏មានប្រសិទ្ធភាពដែលអាចជួយសង្គ្រោះជីវិតកុមារ ដែលបាត់បង់ជាតិទឹកដោយសារជំងឺរាក រូត និងជំងឺផ្សេងៗទៀត។ វាជាបញ្ហាចាំបាច់ ដែលមាតាគ្រប់រូបត្រូវយល់ដឹងឱ្យបានច្បាស់អំពីសារប្រយោជន៍នៃម្សៅអូរ៉ាលីត និងរបៀបប្រើប្រាស់វាឱ្យបានត្រឹមត្រូវ។ ការវាយតម្លៃលើការអង្កេតបានបង្ហាញឱ្យឃើញថា ការយល់ដឹងរបស់

ម្តាយចំពោះការប្រើប្រាស់ម្សៅ អូរ៉ាលីត (ORS) មាន ៩៤% ។ នៅក្នុងចំណោមអ្នកដែលបានដឹងអំពីម្សៅអូរ៉ាលីត ៩៧% បានប្រើប្រាស់សម្រាប់ជំងឺរាក ហើយ ១៤% សម្រាប់ក្អួត និង ១២% សំរាប់មូលហេតុផ្សេងៗទៀត ។ គួរកត់ សម្គាល់ថា សមាមាត្រនៃស្ត្រីដែលបានដឹងអំពីរបៀបប្រើប្រាស់ម្សៅអូរ៉ាលីតត្រឹមត្រូវដែលក្នុង១កញ្ចប់នៃម្សៅអូរ៉ាលីតគឺលាយទឹកឆ្អិនចំណុះមួយលីតមាន ៧៩% ។


ចំណេះដឹងអំពីការប្រើប្រាស់មេរៀនអូរ៉ាលីត
94.8
100
percent
50
5.2
0
Know
Don't know

## ៤.៣ ការយល់ដឹងអំពីជំងឺផ្លូវដង្ហើមស្រួចស្រាវ (ARI)

ARI នៅតែជាមូលហេតុបណ្តាលឱ្យកុមារអាយុក្រោម ៥ ឆ្នាំស្លាប់ក្នុងប្រទេសកម្ពុជា។ ការស្វែងរកសេវាសុខភាពមិនបានត្រឹមត្រូវ និងកង្វះខាតចំណេះដឹងរបស់ម្តាយ ឬ អ្នកមើលថែរទាំកុមារ អំពីសញ្ញាគ្រោះថ្នាក់នៃ ARI លើកុមារជាកត្តាចំបងដែលធ្វើឱ្យកុមារ ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។ ក្នុងចំណោមអ្នកចូលរួម ១១៧ នាក់ ដែលបានសម្ភាស មានតែ ៨% ដែលមិនបានដឹងអ្វីទាំងអស់អំពីសញ្ញាគ្រោះថ្នាក់ធ្ងន់ធ្ងរនៃ ARI។ ប្រជាជនភាគច្រើនបានដឹងអំពី រោគសញ្ញា គ្រុនក្តៅ ៧០.៦% ហៀរសំបោរ ៦០.២% ក្អក ៧៥.២% ចង្វាក់ដង្ហើមញាប់ ៤៨.៧% និងពិបាកដកដង្ហើម ២៧.៧% ថាជាសញ្ញារលាកសួតធ្ងន់ធ្ងរ។


ការប្រៀបធៀបចំណេះដឹងរបស់ម្តាយអំពីសញ្ញានៃការរលាកផ្លូ
វ ដង្ហើមស្រួចស្រាល់
80
60
40
20
0
Percent
70.6
60.2
75.2
25.7
48.7
27.7
5.7
High fever
Runing nose
Cough
Headache
Fash breathing
Breathing dificulty
Don't know
Warning Signs

## ៤.៤ ការយល់ដឹងអំពីជម្ងឺគ្រុនចាញ់ និងការប្រើប្រាស់មុង

ជំងឺគ្រុនចាញ់នៅតែជាបញ្ហាចម្បងនៅក្នុងប្រទេស។ ការយល់ដឹងនិងការអនុវត្តបានត្រឹមត្រូវ អាច ការពារខ្លួនពីការឆ្លងជម្ងឺនេះ។ ការអង្កេតបានបង្ហាញឱ្យឃើញថា ភាគច្រើនលើសលុបនៃប្រជាជនក្នុងតំបន់បានឱ្យដឹងថា ជម្ងឺគ្រុនចាញ់ គឺបណ្តាលមកពីមូសដែកគោលខាំមានប្រមាណ ៩៤.៦% ។ ប្រជាជនដែលមិនបានដឹង អំពីមូលហេតុដែលបណ្តាលឱ្យកើតជំងឺគ្រុនចាញ់មានត្រឹមតែ ៤% ប៉ុណ្ណោះ។ មានតែប្រជាជនមួយផ្នែកតូច ដែលនៅមានជំនឿថា ជំងឺគ្រុនចាញ់បណ្តាលមកពីកត្តាអារក្សអ្នកតា ឬឥទ្ធិពលដទៃទៀត។ ៧៨% នៃអ្នកដែលចូលរួមបាន ឱ្យដឹងថាសមាជិកក្រុមគ្រួសារគាត់ដេកក្នុងមុងជានិច្ចកាល។ សម្រាប់អ្នកដែលមិនបានប្រើប្រាស់មុងឱ្យបានទៀងទាត់ ហើយលទ្ធភាពដែលអាចរកមុងបាន និង លុយដើម្បីទិញមុងហាក់ដូចជាពុំមានបញ្ហាធំដុំទេ មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះ ដែលបានលើកចំណុចនោះជាហេតុផលបញ្ហាចម្បងគឺ ទម្លាប់មិនដេកក្នុងមុង ដែលមានកម្រិតខ្ពស់ ៣៨% ហើយការដែលជឿថា គ្មានមូសនៅក្នុងនិងជុំវិញតំបន់នោះក៏ខ្ពស់ផងដែរ ២៥.៤% មានហេតុផលមិនច្បាស់លាស់ដទៃទៀតបានរួមចំណែកក្នុងការមិនប្រើប្រាស់ឱ្យបានទៀងទាត់។


ចំណេះដឹងស្តីអំពីជំងឺគ្រុនចាញ់
94.6
1.7
1
4
100
80
60
40
20
0
Percent
Moquito bite
Spirit
Other
Don't know
Malaria causes


អត្រានៃការប្រើប្រាស់មុង
78
18
4
80
60
40
20
0
Percent
Always
Sometime
Never


ហេតុផលមិនប្រើប្រាស់មុង
Percent
0
10
20
30
40
50
60
70
80
38.1
9.7
3.2
9.5
25.4
79.4
Don't know
No nets
No money
Not enough net
No mosquitoes
Other

## ៤.៥ ការអនុវត្តការដាំទឹកសម្រាប់បរិភោគ

ជំងឺដែលកើតពីទឹក គឺជាទូទៅកើតនៅក្នុងតំបន់ជនបទ ជាពិសេសនៅក្នុងតំបន់ដែលគ្មានការផ្គត់ផ្គង់ទឹកស្អាត ហើយវាជាការសំខាន់ ដែលប្រជាជនចាត់វិធានការការពារ ដើម្បីការពារខ្លួនពីការកើតជំងឺទាំងនេះ។ វិធីសាមញ្ញបំផុតគឺការផឹកទឹកឆ្អិនជានិច្ច។ ទោះជាយ៉ាងណាក៏ដោយ វាពុំមែនជាការងាយស្រួលទេ ដើម្បីបញ្ចុះបញ្ចូល ដើម្បីឱ្យប្រជាជនចំណាយពេលវេលាបន្តិចបន្តួចក្នុងការដាំទឹកផឹក ទោះបីជាគាត់បានដឹងពីគ្រោះថ្នាក់នៃការពុំបានដាំទឹកផឹកក៏ដោយ។ ការអប់រំសុខភាពគឺជាផ្នែកមួយដ៏ចម្បងក្នុងចំណោមសមាសភាគជាច្រើនរបស់កម្មវិធីជាតិលើកកំពស់សុខភាព។ ជាលទ្ធផលការដាំទឹកសម្រាប់ទទួលទានមានតែ ៧០,៥%។ ចំណែកឯសមាមាត្រនៃគ្រួសារដែលមិនដែលផឹកទឹកឆ្អិនសោះមាន ១៦% ។ ទាំងនេះបញ្ជាក់ថាវាមាន ការងារជាច្រើនត្រូវធ្វើដើម្បីផ្លាស់ប្តូរឥរិយាបថ ក្នុងគោលបំណងធានាសុវត្ថិភាពសហគមន៍ពីជំងឺដែលកើតមក ពីការប្រើប្រាស់ទឹកមិនស្អាត។


ការអនុវត្តក្នុងការដាំទឹកសំរាប់បរិភោគ
70.5
13.5
16
Percent
80
60
40
20
0
Alway
Sometimes
Never

## ៤.៦ ការយល់ដឹងអំពីជំងឺអេដស៍ HIV/AIDS

ជំងឺ HIV/AIDS គឺជាជំងឺមួយដែលជាទូទៅជំងឺរាតត្បាតនៅក្នុងទូទាំងប្រទេស។ ការចម្លងគឺផ្តើមចេញពីក្រុមស្ត្រីរកស៊ីផ្លូវភេទ ទៅកាន់ក្រុមមនុស្សទូទៅ ហើយការចម្លងនេះធ្វើ ឱ្យមានភាពរីករាលដាលពាសពេញផ្ទៃប្រទេស។ មានការខិតខំប្រឹងប្រែងជាច្រើនដើម្បីទប់ស្កាត់ការរីករាលដាលជំងឺនេះ ពីគ្រប់ផ្នែកទាំងអស់ដូចជា ផ្នែកនយោបាយ សង្គម ប្រព័ន្ធព័ត៌មាន ក្រុមអ្នកផ្តល់ជំនួយ ក្រុមគ្រូពេទ្យ និងសហគមន៍ផងដែរ។ ជោគជ័យភាពនៃការគ្រប់គ្រងជំងឺនេះ គឺពឹងផ្អែកទាំងស្រុងទៅលើចំណេះដឹង និងការប្រព្រឹត្តរបស់ប្រជាពលរដ្ឋគ្រប់រូប។ ចំណេះដឹងរបស់ប្រជាជនអំពីជម្ងឺ HIV/AIDS មានការកើនឡើងយ៉ាងខ្លាំងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រជាជនជាង៩០% ដែលបាន សម្ភាសពីជំងឺ HIV/AIDS មានការយល់ដឹងពីជំងឺនេះ។ ការដឹងពីការឆ្លងដ៏ សាមញ្ញបំផុតនៃជំងឺនេះគឺ ៩៣.៦% ពីការរួមភេទ ៧៣% តាមឈាម ឆ្លងតាមរយៈការចាក់ថ្នាំ ៤៥.៤% និង ឆ្លងពីម្តាយទៅកូនមាន ៧៨%។


ចំណេះដឹងអំពីការចម្លងមេរោគអេដស៍
93.6
73
45.4
78
7
7
100
80
60
40
20
0
Percent
Sexual intercourse
Blood transfusion
Injection
Mother to child
Other
Don' t know

## ៤.៧ ការពន្យារកំណើត

ការពន្យារកំណើតគឺជាផ្នែកមួយក្នុងចំណោមផ្នែកទាំងបួននៃមាតុភាពគ្មានគ្រោះថ្នាក់។ ព័ត៌មានស្តីពីវិធីពន្យារកំណើត បានផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈប្រពន្ធ័ផ្សព្វផ្សាយសង្គម សកម្មភាពលើកកំពស់ សុខភាព និងសំភារៈអប់រំ វិធីសាស្រ្តផ្សេងៗជាច្រើនទៀត។ ការយល់ដឹងរបស់ស្រ្តីអំពីវិធីពន្យារកំណើតមានកម្រិតខ្ពស់ ហើយចំនួនស្រ្តីដែលមិនបានដឹងពីការពន្យារកំណើតមានត្រឹមតែ ៣% តែប៉ុណ្ណោះ។ ថ្នាំគ្រាប់ ថ្នាំចាក់ និងស្រោមអនាម័យ គឺជាវិធីសាស្រ្តពេញនិយមបំផុតក្នុងតំបន់ (ថ្នាំគ្រាប់ ៩៦.៣% ថ្នាំចាក់ ៩២.៦% និងស្រោមអនាម័យ ៩៥.៤%) សម្រាប់ស្រ្តីម្នាក់ៗ ឯវិធីសាស្រ្តដាក់កងក្នុងស្បូនក៏កើនឡើងដែរ។ មិនត្រឹមតែចំនួនស្រ្តីដែលបានដឹងអំពីការពន្យារកំណើតប៉ុណ្ណោះទេដែលកើនឡើង ប៉ុន្តែចំណេះដឹងអំពីចំនួនវិធីសាស្រ្តក៏មានការកើនឡើងដែរ ដូចដែលអនុសាសន៍របស់មជ្ឈមណ្ឌលជាតិ គាំពារមាតានិងទារក បានថែងថាស្រ្តីម្នាក់ៗគួរយល់ដឹងយ៉ាងហោចណាស់ ៣ វិធីសាស្រ្តដែរក្នុងការពន្យារកំណើត។ មានស្រ្តី ៨២% បានយល់ដឹងពីវិធីពន្យាកំណើត ៣ ឬច្រើនជាងនេះ បើប្រៀបធៀបទៅនឹងការស្ទង់អង្កេតនៅឆ្នាំ ២០០០ របស់អង្គការអ៊ីតាលី ដែលបានអនុវត្តគម្រោងសុខាភិបាលមូលដ្ឋាននៅតំបន់នោះ មានត្រឹមតែ ៤២%។ យោងតាមតួលេខដែលបានទទួលបុគ្គលិកសុខាភិបាលនិងប្រពន្ធ័ព័ត៌មាន ហាក់មានតួនាទីសំខាន់នៅក្នុងការ ផ្សព្វ

ផ្សាយព័ត៌មានដល់ស្ត្រីស្តីអំពីការពន្យារកំណើត បើប្រៀបធៀបទៅនឹងប្រភពដទៃទៀត។

អត្រាប្រេវ៉ាឡង់ នៃការពន្យារកំណើត ដោយប្រើមធ្យោបាយទាំងឡាយមាន ៤២.៦%។ ក្នុងចំណោមវិធីសាស្ត្រសំខាន់បំផុតដែលបានប្រើ គឺថ្នាំគ្រាប់ ៦៥.៦% ថ្នាំចាក់ ២២.៩%។ ហេតុផលសំខាន់សម្រាប់ការជ្រើសរើសវិធីសាស្ត្រ ក្នុងការពន្យារកំណើតដូចជា ភាពងាយស្រួលក្នុងការប្រើប្រាស់ ៨៨.៥% ផលប៉ះពាល់តិចតួច ៥៦.៣% និងតម្លៃសេវា ១៧.៧% ជាក្រិត្យក្រមដ៏ល្អបំផុតសម្រាប់ស្ត្រីក្នុងការសម្រេចចិត្តជ្រើសរើស វិធីសាស្ត្រពន្យារកំណើត។


ការប្រៀបធៀបចំណេះដឹងនៃវិធីពន្យារកំណើត
Percent
100
80
60
40
20
0
96.3
92.6
95.4
80.7
9.7
7.3
Pill
Injection
Condom
IUD
Other
Don' t know


អត្រាអ្នកប្រើប្រាស់ការពន្យារកំណើត
Percent
70
60
50
40
30
20
10
0
42.6
57.4
used
not used


ហេតុផលសំខាន់ចំពោះស្ត្រីដែលបានប្រើប្រាស់សេវាពន្យារកំណើត
88.5
56.3
17.7
12.5
100
80
60
40
20
0
Percent
Easy
Less side effects
Cheap
Others

## ៤.៨ ការថែទាំផ្ទៃពោះ និងការសម្រាល

ការថែទាំមុនកំណើត គឺជាផ្នែកមួយផ្សេងទៀតនៃមាតុភាពគ្មានគ្រោះថ្នាក់។ វាត្រូវផ្តល់អនុសាសន៍ថា ស្ត្រីមានផ្ទៃពោះត្រូវតែទៅទទួលសេវាគាំពារមុនកំណើតយ៉ាងហោចណាស់ឱ្យបានពីរដង។ សារប្រយោជន៍នៃការគាំពារមុនកំណើតគឺ ជាការពិនិត្យរាល់ស្ថានភាពសុខភាពទូទៅរបស់ស្ត្រីនិងសញ្ញាគ្រោះថ្នាក់ទាំងឡាយ នៃគភ៌អាចរកឃើញទាន់ពេលវេលាដែលដំណាក់កាលនេះអាចចាត់វិធានការការពារ កុំអោយភាពធ្ងន់ធ្ងរកើតមានឡើង ព្រមទាំងការអប់រំអំពីការថែរក្សាគភ៌ អនាម័យចំណីអាហារ ការងារ ការសម្រាលត្រូវផ្តល់ជូនផងដែរ។ ស្ត្រីមានគភ៌ដែលបានទទួលការគាំពារមុនសម្រាល ២ដង ឬលើសពី ២ដងមាន ៧៣.៤%។ ចំពោះទីកន្លែងដែលស្ត្រីទទួលសេវាថែទាំ គឺ ៦៤% ទទួលការថែទាំនៅតាមភូមិតាមរយៈការធ្វើសកម្មភាពចាក់ថ្នាំបង្ការនិងពិនិត្យគភ៌តាមមូលដ្ឋាន ហើយមានតែ ៣២% ប៉ុណ្ណោះប្រើប្រាស់សេវានៅមណ្ឌលសុខភាព ចំណែកការពិនិត្យនៅមន្ទីរបង្អែកមានតិចតួច ដោយសារបញ្ហាភូមិសាស្ត្រ។

ដូចជាការថែរក្សាមុនសម្រាលដែរ ការចាក់ថ្នាំបង្ការតេតាណូស ត្រូវផ្តល់អនុសាសន៍ដល់ស្ត្រីមាន ផ្ទៃពោះ យ៉ាងតិច២ដង ដោយសារការរាលដាលនៃតេតាណូសកុមារនៅតែកើតមាន។ ចំនួនស្ត្រីដែលបានចាក់លើសពី ពីរដងមាន ៨០.៧%។

សុវត្ថិភាពសម្រាលជាការសំខាន់ក្នុងការកំណត់ការស្លាប់របស់ម្តាយ។ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលបានខិតខំធ្វើការដើម្បីកាត់បន្ថយគ្រោះថ្នាក់នៅពេលសម្រាលនេះ ពួកគេបានលើកទឹកចិត្តដល់ឆ្មបបុរាណ ឱ្យបញ្ជូនស្ត្រី មកសម្រាលនៅមណ្ឌលសុខភាព និងជួយបង់ថ្លៃសេវាផ្សេងៗ។ អត្រាសម្រាលកូននៅ មណ្ឌលសុខភាព មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺ ៥២% បើប្រៀបធៀបទៅនឹងរបាយការណ៍របស់ មណ្ឌលសុខភាពស្រុកអូរាំងនាឆ្នាំ ២០០០ ឃើញថាស្ត្រី ៩៥% នៅក្នុងតំបន់សម្រាលកូនតាមផ្ទះហើយ មួយចំនួនតូចសម្រាលនៅមណ្ឌលសុខភាព។ ប៉ុន្តែតួលេខនេះវានៅតែមានកំរិតទាបដែលមើលទៅសេវាសុខភាពសាធារណៈ ដូចជាមិនទាន់ផ្តល់សេវាគ្រប់គ្រាន់នៅឡើយ។ ការជ្រើសរើសទីកន្លែងសម្រាលកូន គឺបណ្តាលមកពីការធ្វើដំណើរ ភាពងាយស្រួលរក និង គុណភាពរបស់សេវានៅនឹងកន្លែងផងដែរ។

ការសិក្សាស៊ីជម្រៅលើ ឥរិយាបថរបស់ប្រជាជនដែលមិនព្រមមកសម្រាលកូននៅសេវាសាធារណៈ គួរតែស្វែងយល់រកឫសគល់ ពីហេតុផលចម្បងបន្ថែមទៀត។ មន្ទីរសម្ភព គឺជាកន្លែងសម្រាលកូន ដែលប្រកបដោយសុវត្ថិភាព។ នៅឯមណ្ឌលសុខភាពគួរតែមានសំភារៈគ្រប់គ្រាន់ និង គ្មានការឆ្លងរោគ ហើយការបញ្ជូនទៅមន្ទីរពេទ្យបង្អែក ត្រូវធ្វើឱ្យបានទាល់ពេលវេលាក្នុងករណីចាំបាច់។ ក៏ប៉ុន្តែនៅកន្លែងណាក៏ដោយ វាជាការល្អប្រសើ បើសិនជាការសម្រាលកូននោះធ្វើឡើងដោយឆ្មប ដែលមានការបណ្តុះបណ្តាលនិងមាន

បទពិសោធន៍ ។ សមាមាត្រនៃការសម្រាលកូនធ្វើឡើងដោយឆ្មបពេទ្យមាន ៩១% នេះដោយសារឆ្មប បុរាណមិនអនុញ្ញាតឱ្យសម្រាលទៀតឡើយ ។



អត្រានៃការពិនិត្យផ្ទៃពោះ
percent
80
70
60
50
40
30
20
10
0
9
17.6
73.4
none
one
two or more


ការប្រៀបធៀបចំនួនដងនៃស្ត្រីដែលបានទទួលថ្នាំបង្ការតេតាណូស
Percent
80
60
40
20
0
3.1
28.7
68.2
None
One
Two or more


ទីកន្លែងដែលស្ត្រីបានជ្រើសរើសដើម្បីពិនិត្យផ្ទៃពោះ
percent
70
60
50
40
30
20
10
0
Village
Health Center
Referal Hospital


អត្រាកន្លែងសម្រាល
Percent
53
52
51
50
49
48
47
46
45
47.7
52.3
Home
Health facilities

## ៤.៩ ការថែទាំនិងការបំបៅដោះកូន

ការបីបាច់ថែរក្សាកូនគឺជាកត្តាសំខាន់បំផុត។ ទឹកដោះម្តាយ ជាពិសេសទឹកដោះដំបូង (colostrum) មានសារធាតុចិញ្ចឹមគ្រប់គ្រាន់ និង មានមុខងារសំខាន់ ជួយបន្សាត់អាចម៍ព្រៃនាំអង់ទីករពីម្តាយមកកូននិង ទប់ស្កាត់ជំងឺរលាកផ្លូវអាហារ (gastroenteritis) ទៀតផង ដែលជាហេតុធ្វើឱ្យកុមារលូតលាស់និងមានសុខភាពល្អ។ មិនត្រូវច្របាច់ទឹកដោះដំបូងចោលទេ ហើយត្រូវតែឱ្យកូនបៅទឹកដោះដំបូងនោះក្នុងកំលុង ១ ម៉ោងដំបូងបន្ទាប់ពីសម្រាលរួច ហើយការបំបៅដោះតែមួយមុខសុទ្ធត្រូវតែបន្តយ៉ាងហោចណាស់ឱ្យទារកមានអាយុ៦ខែ។ ការអង្កេតបានបង្ហាញថា ម្តាយដែលឱ្យកូនបៅទឹកដោះដំបូងមាន ៩២.៧% ។ ចំនួនម្តាយដែលផ្តល់ចំណីអាហារផ្សេងៗទៀតក្រៅពីទឹកដោះម្តាយទៅឱ្យកូន មុនបំបៅដោះដំបូងមានការថយចុះមកនៅត្រឹម ១២% ប៉ុណ្ណោះ នេះមានន័យថាប្រជាជនមានការយល់ដឹងច្រើនពីអត្ថប្រយោជន៍ នៃការបំបៅដោះ តែមួយមុខ។ ពេលវេលានិងគុណភាពចំណីអាហារបន្ថែមដែលត្រូវផ្តល់ឱ្យទរក មានសារសំខាន់ដល់ការលូតលាស់និងសុខភាព។ អាហារបំប៉នបន្ថែមត្រូវផ្តល់ឱ្យទារកចាប់ពីអាយុ ៦ ខែឡើងទៅ។ ការអង្កេតបានបង្ហាញថា ៣៣% នៃម្តាយនៅតែឆាប់ផ្តល់អាហារបន្ថែមដល់កុមារ។ ដូចគ្នានេះដែរ រយៈពេលបំបៅដោះកូនមានរយៈពេលខ្លីមាន ៧០% នៃម្តាយបានបញ្ឈប់ការបំបៅដោះ មុនកូនរបស់ខ្លួនអាយុបាន១២ខែ។ ដូច្នេះការសិក្សា

លម្អិតបន្ថែមទៀតលើការបំបៅដោះ និងរកហេតុផលឱ្យបានច្បាស់នៅពីក្រោយបញ្ហានេះ។


ការប្រៀបធៀបអោយុរបស់កុមារដែលចាប់ផ្តើមផ្តល់អាហារបន្ថែម
មុនដំបូង
Percent
45
40
35
30
25
20
15
10
5
0
33.3
43
23.7
<4months
4-6months
7months+

ការប្រៀបធៀបអាយុកុមារនៅពេលផ្ដាច់ដោះ



# ៥, សេចក្តីសន្និដ្ឋាន

ការសិក្សានេះធ្វើឡើងក្នុងគោលបំណង ប្រមូលទិន្នន័យអំពីឥរិយាបថរបស់ប្រជាជនអំពីបញ្ហាសុខភាព សូចនាករអំពីសុខភាព និងចំណេះដឹងរបស់សហគមន៍អំពីជំងឺឆ្លងនៅលើក្រុមគោលដៅ។ តាមការវិភាគបានបង្ហាញឱ្យឃើញអំពីលទ្ធផលវិជ្ជមាន បើប្រៀបធៀបទៅនឹងស្ថានភាពសុខភាពនៅឆ្នាំ ២០០៥។ មណ្ឌលសុខភាព បានដើរតួយ៉ាងសំខាន់នៅក្នុងការបម្រើសេវាសុខាភាពជូនប្រជាជន។ គេសង្កេតឃើញថាមាន ប្រជាជន ៧១% បានជ្រើសរើសមណ្ឌលសុខភាព ជាជម្រើសទីមួយនៅពេលពួកគាត់មានបញ្ហាសុខភាព។ ទន្ទឹមនឹងនេះដែរ ស្ត្រីជាម្តាយមានការយល់ដឹងខ្ពស់អំពីការប្រើប្រាស់ម៉្សៅអូរាលីត និងសញ្ញាគ្រោះថ្នាក់របស់ ជំងឺរលាកផ្លូវដង្ហើមស្រួចស្រាល់។ ចំណេះដឹងអំពីជំងឺគ្រុនចាញ់ ការប្រើប្រាស់មុងបានទទួលលទ្ធផលជាវិជ្ជមាន ការដែលមិនទំលាប់ដេកក្នុងមុង គឺជាមូលហេតុចម្បងមួយដែលធ្វើឱ្យប្រជាជនមិនប្រើប្រាស់មុង។ ភាគរយនៃគ្រួសារដែលទទួលទានទឹកឆ្អិន មានការកើនឡើងគួរឱ្យកត់សម្គាល់ ហើយទម្លាប់ផឹក ទឹកឆៅមានការថយចុះ ក៏ប៉ុន្តែគេត្រូវខិតខំបន្ថែមទៀតដើម្បីជួយដល់ប្រជាជនឱ្យមានការយល់ដឹង និងផ្លាស់ប្តូរនូវការប្រព្រឹត្ត។ ចំណេះដឹងរបស់ប្រជាជនអំពីមេរោគអេដស៍ជំងឺអេដស៍ក៏មានការកើនឡើងដែរ ជាពិសេសស្ត្រីជាម្តាយដែលបានដឹង អំពីការចម្លងពីម្តាយទៅ

កូន។ សកម្មភាពពន្យារកំណើត និងស្ត្រីដែលបានទទួលស្គាល់អំពីផលប្រយោជន៍ របស់កម្មវិធីពន្យារកំណើតមានកម្រិតកើនឡើងខ្ពស់ ហើយចំនួនស្ត្រីដែលមិនបានដឹងពីការពន្យារកំណើតមានត្រឹមតែ ៣% តែប៉ុណ្ណោះ។ ការសម្រាលកូននៅមណ្ឌលសុខភាពមានការកើនឡើងគួរកត់សម្គាល់ តែវានៅមានកម្រិតទាបនៅឡើយ ដែលយើងត្រូវសិក្សាបន្ថែមទៀតដើម្បីរកមើលពីមូលហេតុនៃការមិនជ្រើសរើស យកមណ្ឌលសុខភាពដើម្បីសម្រាលកូន។ តែទោះជាយ៉ាងណាក៏ដោយ ៩១% នៃការសម្រាលនេះធ្វើឡើងដោយឆ្មបដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ឯឆ្មបបុរាណ គឺមិនអនុញ្ញាតឱ្យសម្រាលទៀតឡើយ។ ការអនុវត្តការបំបៅដោះមានការកែប្រែជាវិជ្ជមាន ស្ត្រីជាង ៩២.៧% បានបំបៅដោះកូនដោយទឹកដោះដំបូង ហើយការបំបៅដោះតែមួយមុខឱ្យបានរយៈពេល៦ខែនៅមានកម្រិតទាបនៅឡើយ។

## ៦. សំណូមពរ

ដើម្បីឱ្យប្រជាជននៅតំបន់ដែលយើងបានធ្វើអង្កេតនេះមានស្ថានភាពសុខភាពកាន់តែប្រសើរជាងនេះទៅទៀត ក្រុមស្រាវជ្រាវសូមសំណូមពរ មួយចំនួនដូចខាងក្រោមៈ

- ក្រសួង អង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍គួរបន្តការអប់រំផ្សព្វផ្សាយឱ្យប្រជាជន មករកសេវាថែទាំសុខភាព នៅឯមណ្ឌលសុខភាព ឬសេវាសាធារណៈ។

- ក្រសួង ស្ថានប័នពាក់ព័ន្ធគួរបន្តការអប់រំផ្សព្វផ្សាយឱ្យប្រជាជនប្រើប្រាស់មុងជាប្រចាំនៅពេល សម្រាន្តទាំងថ្ងៃទាំងយប់ ជាពិសេសនៅពេលធ្វើដំណើរទៅព្រៃ។

- ក្រសួង ស្ថានប័នពាក់ព័ន្ធ គួរបន្តការអប់រំផ្សព្វផ្សាយនឹងលើកទឹកចិត្តឱ្យស្ត្រីមានផ្ទៃពោះមកប្រើប្រាស់សេវាពិនិត្យ និង សម្រាលកូននៅមណ្ឌលសុខភាព និង ជាមួយឆ្មបជំនាញ ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវពីក្រសួងសុខាភិបាល។

- ក្រសួង ស្ថានប័នពាក់ព័ន្ធ គួរបន្តការអប់រំផ្សព្វផ្សាយឱ្យស្ត្រីជាម្តាយបំបៅដោះកូន ដោយទឹកដោះ ម្តាយតែមួយមុខឱ្យបាន៦ខែ និង បន្តបំបៅដោះកូនឱ្យបានលើសពីមួយឆ្នាំដើម្បីឱ្យទារកមានសុខភាពល្អ។

- ក្រសួង ស្ថានប័នពាក់ព័ន្ធគួរជួយផ្តល់មធ្យោបាយដឹកជញ្ជូនអ្នកជំងឺសម្រាប់ដឹកអ្នកជំងឺមកកាន់មណ្ឌលសុខភាពឬមន្ទីរពេទ្យបង្អែកខេត្តក្នុងករណីចាំបាច់ ។

- បន្តពង្រឹងចំណេះដឹងដល់ភ្នាក់ងារស្ម័គ្រចិត្តសុខាភិបាល និងមន្ត្រីសុខាភិបាលជាប្រចាំ ដោយមានការលើកទឹកចិត្តដល់អ្នកដែលធ្វើការឆ្ងាយពីទីប្រជុំជនតាមរយៈបណ្ណសសើរនិងប្រាក់រង្វាន់ជាដើម ។ល ។